# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៥៣ ទក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋាន នៃក្រសួងទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋាន នៃក្រសួងទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានានូវប្រសិទ្ធិភាពការងារ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គាធិការដ្ឋានទេសចរណ៍៖
- ធានាគុណផលការងារប្រកបដោយប្រសិទ្ធភាព និងគុណភាព
- ជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តិនានាប្រកបដោយប្រសិទ្ធិភាព។

ផ្ទះលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**អគ្គាធិការដ្ឋាន** ជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារអធិការកិច្ច អង្កេត ស្រាវជ្រាវគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងអាជីវកម្ម សេវាកម្មទេសចរណ៍ ក្នុងករណីមានភាពមិនប្រក្រតី ឬអនុវត្តផ្ទុយទៅនឹងច្បាប់ក្នុងវិស័យទេសចរណ៍។

**អគ្គាធិការដ្ឋាន** មានតួនាទី និងភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ដោយមានការណែនាំរបស់ប្រធានស្ថាប័ន
- ស្រាវជ្រាវ អង្កេត និងធ្វើអធិការកិច្ចលើប្រតិបត្តិករ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ ក្នុងករណីមានភាពមិនប្រក្រតី នៃការប្រកបអាជីវកម្មសេវាកម្មទេសចរណ៍ ឬការអនុវត្តផ្ទុយទៅនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យទេសចរណ៍
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការចាត់វិធានការលើភាពមិនប្រក្រតីក្នុងវិស័យទេសចរណ៍
- ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវម្មលើទីបរិវេណ ឬសម្ភារៈដែលបានប្រើប្រាស់ ឬសង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- កសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសទេសចរណ៍បញ្ជូនទៅតុលាការ
- អធិការកិច្ចជាបន្ទាន់ក្នុងករណីចាំបាច់ក្រោមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការ **មួយ(០១)រូប** អមដោយអគ្គាធិការរង និងអធិការមួយចំនួនតាមការចាំបាច់។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

អគ្គាធិការដ្ឋាន មានការិយាល័យចំណុះចំនួន **០៤(បួន)** ដូចខាងក្រោម៖

១-ការិយាល័យទទួល និងដោះស្រាយបណ្តឹងទេសចរណ៍

២-ការិយាល័យអង្កេតស្រាវជ្រាវ

៣-ការិយាល័យអធិការកិច្ចទេសចរណ៍

៤-ការិយាល័យសរុប និងតាមដានការអនុវត្ត ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់អគ្គាធិការដ្ឋាន ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យទទួល និងដោះស្រាយបណ្តឹងទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- ត្រួតពិនិត្យ និងដោះស្រាយរាល់ពាក្យបណ្តឹងទេសចរណ៍ដែលកើតមានឡើងពាក់ព័ន្ធវិស័យទេសចរណ៍
- ទទួលពាក្យបណ្តឹងរបស់ភ្ញៀវទេសចរ មន្ត្រីរាជការ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- ពិនិត្យ រៀបចំធ្វើបែបបទបញ្ជូនពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ
- ដោះស្រាយបណ្តឹងចំពោះមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ នៅតាមរាជធានី ខេត្ត
- ជាលេខាធិការដ្ឋានឱ្យគណៈកម្មការដោះស្រាយវិវាទទេសចរណ៍
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលកើតមានខុសភាពប្រក្រតី។

**២-ការិយាល័យអង្កេតស្រាវជ្រាវ** មានតួនាទី និងភារកិច្ច៖

- អង្កេតតាមដាន និងស្រាវជ្រាវរាល់បាតុភាពផ្សេងៗលើបណ្តឹងតវ៉ា និងវិវាទដែលប៉ះពាល់ ឬរាំងស្ទះដល់គោលនយោបាយអភិវឌ្ឍវិស័យទេសចរណ៍ជាតិ
- សហការចុះអង្កេតស្រាវជ្រាវ និងទទួលដោះស្រាយវិវាទទេសចរណ៍ដែលកើតមានរវាងមូលដ្ឋានអាជីវកម្ម ជាមួយនឹងមូលដ្ឋានអាជីវកម្ម ឬមូលដ្ឋានអាជីវកម្ម ជាមួយនឹងភ្ញៀវទេសចរ
- ធ្វើអង្កេតស្រាវជ្រាវបន្ទាន់លើបាតុភាពផ្សេងទៀត ដែលកើតឡើងជាយថាហេតុតាមការប្រគល់ភារកិច្ចពីថ្នាក់ដឹកនាំក្រសួង
- ធ្វើអង្កេតស្រាវជ្រាវឡើងវិញលើលទ្ធផលអធិការកិច្ចទាំងឡាយ ដែលមានការតវ៉ាថាមានភាពមិនប្រក្រតីពីសំណាក់មជ្ឈដ្ឋានដែលមានបាតុភាព រួចធ្វើរបាយការណ៍ប្រៀបធៀប និងធ្វើសន្និដ្ឋានជូនថ្នាក់ដឹកនាំ។

**៣-ការិយាល័យអធិការកិច្ចទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- ធ្វើអធិការកិច្ចលើវិស័យទេសចរណ៍ដែលមានវិសាលភាពលើអង្គភាពចំណុះក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត អំពីការងារបច្ចេកទេស និងសេវាកម្មទេសចរណ៍
- អធិការកិច្ចលើការងារបច្ចេកទេស និងការអនុវត្តន៍ច្បាប់របស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍នៅតាមបណ្តារាជធានី ខេត្ត
- សហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានាដើម្បីអធិការកិច្ចក្នុងករណីមិនប្រក្រតី
- ស្រាវជ្រាវរកវិធីសាស្ត្រថ្មីៗនានាដើម្បីជំរុញការធ្វើអធិការកិច្ចឱ្យមានប្រសិទ្ធិភាព។

**៤-ការិយាល័យសរុប និងតាមដានការអនុវត្ត** មានតួនាទី និងភារកិច្ច៖

- រៀបចំគម្រោងថវិការកម្មវិធី និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទំនាក់ទំនង និងបដិសណ្ឋាកិច្ចជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធ និងប្រតិបត្តិករទេសចរណ៍
- ធ្វើផែនការ និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យអគ្គាធិការដ្ឋាន មានតួនាទី និងភារកិច្ច៖

- លើកគម្រោងផែនការការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនអគ្គាធិការ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គាធិការ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.–**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ